# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០៤ ខែមេសា ឆ្នាំ២០២៤



ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com


## មាតិកា


- ពិធីបើកយុទ្ធនាការជិះកង់រៃអង្គាសថវិកាជួយទ្រទ្រង់មូលនិធិគន្ធបុប្ផា
- ពិសោធ៖ ចំហេះម៉ាញេស្យូម
- គ្រូបង្រៀននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ទទួលបានជ័យលាភីចំនួនពីរក្នុងឆ្នាំតែមួយ
- ការប្រជុំបូកសរុបលទ្ធផលឆមាសទី១
- ការរៀបចំពិធីសូត្រមន្តឆ្នាំថ្មី
- សិក្ខាសាលាស្ដីអំពី គន្លឹះដើម្បីត្រៀមខ្លួនដាក់អាហារូបករណ៍


## ពិធីបើកយុទ្ធនាការជិះកង់រៃអង្គាសថវិកាជួយទ្រទ្រង់មូលនិធិគន្ធបុប្ផា




ពាមជីកង៖ នាព្រឹកថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ រដ្ឋបាលស្រុកកងមាសបានប្រារព្ធពិធីបើកយុទ្ធនាការជិះកង់រៃអង្គាសថវិកាជួយទ្រទ្រង់មូលនិធិគន្ធបុប្ផា ក្រោមអធិបតីភាពលោក ភោគ សាវុធ អភិបាលនៃគណៈអភិបាលស្រុកកងមាស និងក្រុមប្រឹក្សាស្រុក ដោយមានការចូលរួមពីលោកមេឃុំពាមជីកង ក្រុមប្រឹក្សាឃុំ គណៈនាយក លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ព្រមទាំងប្រជាពលរដ្ឋក្នុងឃុំ ប្រមាណ ២០០នាក់ ដោយបានបែងចែកពីរក្រុមគឺ៖

- ក្រុមទី១ដឹកនាំដោយលោក ភោគ សាវុធ អភិបាលនៃគណៈអភិបាលស្រុកកងមាស ដែលចេញដំណើរពីការិយាល័យ អ.យ.ក ស្រុក ទៅព្រំប្រទល់ឃុំអង្គរបាន
- ក្រុមទី២ ដឹកនាំដោយលោក ម៉ុក រ៉ាសឿន អភិបាលរងស្រុក ដែលចេញដំណើរពីការិយាល័យ អ.យ.ក ស្រុក ទៅព្រំប្រទល់ឃុំព្រែកក្របៅ។

ខាងក្រោមនេះគឺជាសកម្មភាពក្រុមទី២ ដែលមានមុខព្រួញទៅព្រំប្រទល់ឃុំព្រែកក្របៅ។









# ពិសោធ៖ ចំហេះម៉ាញេស្យូម



ពាមជីកង៖ នាព្រឹកថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ លោកគ្រូ មឿន ស៊ីនីត គ្រូបង្រៀនមុខវិជ្ជាគីមីវិទ្យា បានដឹកនាំសិស្សថ្នាក់ទី៨P2 ធ្វើការពិសោធទៅលើ ចំហេះម៉ាញេស្យូម ដើម្បីឱ្យសកម្មភាពរៀនកាន់តែមានភាពទាក់ទាញ និងសិស្សានុសិស្សយល់កាន់តែច្បាស់។ ជាមួយគ្នានេះដែរ លោកគ្រូ បានបង្រៀនសិស្សដោយប្រើប្រាស់៖

គោលវិធី៖ ស្ថាបនានិយម

វិធីសាស្ត្រ៖ IBL

ខាងក្រោមនេះជារូបភាពអំពីការពិសោធ៖








# គ្រូបង្រៀននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ទទួលបានជ័យលាភី ចំនួនពីរក្នុងឆ្នាំតែមួយ



លោក ឃុយ ម៉េងឃី ជាគ្រូបង្រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ផ្នែកអក្សរសាស្ត្រខ្មែរ។ លោកមានស្រុកកំណើតនៅភូមិពង្រ ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម និងជាអតីតសិស្សនៃវិទ្យាល័យមួយនេះតែម្តង។ ក្រោយពេលបញ្ចប់ថ្នាក់វិទ្យាល័យ លោកបានបន្តសិក្សាថ្នាក់ឧត្តមសិក្សា និងបានប្រឡងជាប់ក្លាយជាគ្រូបង្រៀនកម្រិតឧត្តមបរិញ្ញា+១ ឯកទេសអក្សរសាស្ត្រខ្មែរ-ប្រវត្តិវិទ្យា ហើយក៏បានត្រឡប់មកបង្រៀននៅវិទ្យាល័យក្នុងស្រុកកំណើតនេះវិញចាប់ពីឆ្នាំ២០១៤មក។

ក្នុងអាជីពជាគ្រូបង្រៀន លោកគ្រូបានចំណាយពេល និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្រៀនសិស្សានុសិស្ស ពីព្រោះថាការងារជាគ្រូបង្រៀននេះ គឺជាការងារក្នុងក្តីស្រមៃរបស់លោកគ្រូតាំងពីកុមារភាពមកម្ល៉េះ។ លោកគ្រូតែងទទួលបានការលើកសរសើរពីគណៈនាយក លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សថា លោកជាគ្រូបង្រៀនម្នាក់ដ៏ល្អ។ ក្រៅពីការបង្រៀន លោកគ្រូបានឆ្លៀតឱកាសក្នុងការបង្កើនគុណវុឌ្ឍិរបស់ខ្លួនរហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញភាសាវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្រៅពីនេះ លោកគ្រូតែងចូលរួមសកម្មភាពនៅក្នុងសង្គម សកម្មភាពក្នុងសាលាជារឿយៗមិនដែលអាក់ខានឡើយ ជាពិសេសលោកគ្រូមានជំនាញជាអ្នកសម្របសម្រួលកម្មវិធី(MC)ស្ទើរតែគ្រប់កម្មវិធីទាំងអស់នៅក្នុងសាលា ក៏ដូចជានៅក្នុងស្រុកកងមាសទាក់ទងទៅនឹងការងារវិស័យអប់រំ។






ដោយសារតែស្នាដៃក្នុងការងារអប់រំ នៅក្នុងឆ្នាំសិក្សា២០២២-២០២៣ លោកគ្រូត្រូវបានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ជ្រើសរើសជាបេក្ខភាពគ្រូបង្រៀនល្អកម្រិតមធ្យមសិក្សាទុតិយភូមិ និងទទួលបានចំណាត់ថ្នាក់លេខ១ទូទាំងខេត្តកំពង់ចាម។ បន្ទាប់មក លោកគ្រូត្រូវបានក្រុមការងារក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តម អ៊ុង ជិនណា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ចុះវាយតម្លៃស្របតាមសូចនាករវាយតម្លៃគ្រូបង្រៀនល្អកាលពីខែមីនាកន្លងទៅ។ ជាលទ្ធផល លោកគ្រូទទួលជ័យលាភីពានរង្វាន់ចំណាត់ថ្នាក់លេខ២ និងថវិកាអមពានចំនួន៤លានរៀល។ ស្របគ្នានេះដែរ នៅក្នុងឆ្នាំ២០២៤ដដែលនេះ លោកគ្រូបានសរសេរអត្ថបទចូលរួមប្រកួតប្រជែងបកស្រាយប្រធានបទ “តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌” ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៩ ឆ្នាំ២០២៤ ក្រោមប្រធានបទ **“អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត”**។ ជាលទ្ធផល លោកគ្រូទទួលបានចំណាត់ថ្នាក់លេខ៣ ក្នុងចំណោមបេក្ខជនជាង ៧០នាក់/អង្គ។ លោកគ្រូបានមានប្រសាសន៍ថា៖ “នេះជាលើកទីបីហើយដែលលោកគ្រូបានចូលរួមប្រកួតប្រជែង ហើយការប្រកួតមុនៗ លោកគ្រូពុំដែលទទួលបានភាពជោគជ័យឡើយ”។ ត្រង់ចំណុចនេះដែរ លោកគ្រូបានលើកឡើងថា ទាល់តែមានសេចក្តីព្យាយាមជារឿយៗ ទើបបានសម្រេច។ បើមិនជោគជ័យ សូមកុំបោះបង់ ត្រូវតែមានសេចក្តីព្យាយាម ស្របតាមសុភាសិតរបស់ដូនតាខ្មែរដែលបានចែងថា “តក់ៗពេញបំពង់”។

# ការប្រជុំបូកសរុបលទ្ធផលឆមាសទី១









នៅព្រឹកថ្ងៃព្រហស្បតី ទី៤ ខែមេសា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រជុំបូកសរុបលទ្ធផលឆមាសទី១ ដោយលើកពីចំណុចល្អ ចំណុចប្រឈម និងលើកទិសដៅសម្រាប់ឆមាសទី២ ដោយមានការអញ្ជើញចូលរួមពីគណៈកម្មការគ្រប់គ្រងសាលា គណៈនាយក និងលោកគ្រូអ្នកគ្រូ។









# ការរៀបចំពិធីសូត្រមន្តឆ្នាំថ្មី



ពាមជីកង៖ នាព្រឹកថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំប្រារព្ធពិធីសូត្រមន្តអបអរសាទរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដើម្បីសុំសេចក្ដីសុខ សិរីសួស្ដី ដល់បុគ្គលិកទាំងអស់។

ក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត ប្រសិទ្ធិពរជ័យ សិរីមង្គល មានការអញ្ជើញចូលរួមពីសំណាក់ លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ ជាច្រើនរូប។ ពិធីនេះបានប្រារព្ធឡើងទៅតាមគន្លងទំនៀមទំលាប់ប្រពៃណី ព្រះពុទ្ធសាសនា ដោយបាននិមន្តព្រះសង្ឃសូត្រមន្តចំរើនព្រះបរិត្ត សមាទានសីល និងសូមទេវតាឆ្នាំថ្មី សូមជួយប្រោះព្រំពរជ័យសិរីសួស្ដី វិបុលសុខមហាប្រសើរ សុំសេចក្ដីសុខ សេចក្ដីចំរើនជូនដល់បុគ្គលិកទាំងអស់។









# សិក្ខាសាលាស្ដីអំពី គន្លឹះដើម្បីត្រៀមខ្លួនដាក់អាហារូបករណ៍



ពាមជីកង៖ នាព្រឹកថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំសិក្ខាសាលាស្ដីពី “គន្លឹះដើម្បីត្រៀមខ្លួនដាក់អាហារូបករណ៍” ដល់សិស្សានុសិស្សថ្នាក់ទី១២ ដែលចូលរួមចែករំលែកដោយវាគ្មិនលោកស្រី ស៊ីម ផល្លី ក្នុងកម្មវិធីនេះដែរ លោកស្រីបានចែករំលែកដូចជា៖

- ការស្រាវជ្រាវពីព័ត៌មានអាហារូបករណ៍
- ការរៀបចំឯកសារដើម្បីដាក់ពាក្យអាហារូបករណ៍
- ការត្រៀមខ្លួនដើម្បីប្រឡង និងសម្ភាសន៍។

ដើម្បីឱ្យសិស្សានុសិស្សគាត់យល់ដឹងពីវិធីដាក់អាហាររូបករណ៍។ កម្មវិធីនេះប្រព្រឹត្តទៅពីម៉ោង ៨:០០ ដល់ ១០:០០ នាទីព្រឹក នៅសាលប្រជុំអគារធនធាននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដែលរៀបចំ និងសម្របសម្រួលដោយ សេវាប្រឹក្សាអាជីពគឺអ្នកគ្រូ អាត ណារី។











